ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែសីហា ឆ្នាំ២០២០

នៅក្នុងខែសីហា ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ

-អនុញ្ញាតឱ្យបេក្ខជនជ័យលាភីអាហារូបករណ៍ជប៉ុន(Japan Development Scholarship-JDS) ចំនួន២៤រូប ចូលជួបសម្តែងការគួរសម និងទទួលអនុសាសន៍ណែនាំ។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-អញ្ជើញចូលរួមពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប១០០ថ្ងៃ ឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធអ្នកឧកញ៉ាព្រឹទ្ធមហាឧបាសិកា ធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** នៅភូមិគ្រឹះសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមពិធីសូត្រមន្តប្រោះព្រំអាស្រមមរតកចក្រី នៅភូមិគ្រឹះសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ក្នុងភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

-អញ្ជើញចូលរួមពិធីស្រោចស្រពសុគន្ធវារី និងប្រកាសតែងតាំង ព្រះគ្រូឧត្តមរតនញ្ញាណ **ម៉ុក គឹមសាន** ព្រះគ្រូចៅអធិការវត្ត ឡើងងារជាព្រះមេត្តានុភ័ទ្ទ ព្រះរាជាគណៈថ្នាក់កិត្តិយស នៅវត្តគិរីសុវណ្ណារាម(ហៅវត្តថ្កូវ) ស្ថិតក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

**គ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញចុះសាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរមូលដ្ឋាន នៅសង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

-អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាស្រុកឃុំ នៅស្រុករមាសហែក ខេត្តស្វាយរៀង ស្រុកកញ្ច្រៀច ខេត្តព្រៃវែង និងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

**ឃ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២០ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ព្រឹទ្ធសភា**

**ក-សកម្មភាពចូលរួមពិធីផ្សេងៗ**

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធឯកឧត្តម **ឡឺ ខា ភៀ** **(Le Kha Pieu)** អតីតអគ្គលេខាធិការនៃបក្សកុម្មុនីស្តវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្ថានទូតវៀតណាម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញចូលរួមពិធីស្រោចស្រពសុគន្ធវារី និងប្រកាសតែងតាំង ព្រះគ្រូឧត្តមរតនញ្ញាណ **ម៉ុក គឹមសាន** ព្រះគ្រូចៅអធិការវត្ត ឡើងងារជាព្រះមេត្តានុភ័ទ្ទព្រះរាជាគណៈថ្នាក់កិត្តិយស នៅវត្តគិរីសុវណ្ណារាម(ហៅវត្តថ្កូវ) ស្ថិតក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

-អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីសូត្រមន្តប្រោះព្រំអាស្រមមរតកចក្រីជូនសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចធម្មវិសុទ្ធវង្សា **សៅ ទី ហេង សំរិន** និងពិធីជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងអាជ្ញាធរឃុំ សង្កាត់ ក្រុង ស្រុក នៃខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង នៅភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ខែព ឯន អនុប្រធានទី២ ព្រឹទ្ធសភា**

ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ

-អនុញ្ញាតឱ្យក្រុមការងាររាជបណ្ឌិតសភាកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិតសភាកម្ពុជា និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សាបណ្ឌិតសភាចារ្យធ្វើការសម្ភាស ដើម្បីរៀបចំគុណកថាលម្អិត សម្រាប់ពិធីប្រកាសគោរមងារកិត្តិយសដែល**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យត្រាស់បង្គាប់

ផ្តល់គោរមងារកិត្តិយស នៃរាជបណ្ឌិតសភាកម្ពុជា ជា "កិត្តិសង្គហបណ្ឌិត"។

**ខ-សកម្មភាពចុះមូលដ្ឋាន**

-អញ្ជើញដឹកនាំគណៈប្រតិភូក្រុមសមាជិកាព្រឹទ្ធសភាទៅទស្សនកិច្ច និងសំណេះសំណាល ព្រមទាំងចែកអំណោយដល់ប្រជាពលរដ្ឋចំនួន៣៥០នាក់ នៅភូមិអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីសូត្រមន្តប្រោះព្រំអាស្រមមរតកចក្រីជូនសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចធម្មវិសុទ្ធវង្សា **សៅ ទី ហេង សំរិន** និងពិធីជួបសំណេះសំណាលជាមួយមន្ត្រីរាជការ និងអាជ្ញាធរឃុំ សង្កាត់ ក្រុង ស្រុក នៃខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង នៅភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែសីហានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះសិក្សាឈ្វេងយល់អំពីការប្រមូលព័ត៌មាន ការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ច របស់គណៈកម្មការ នៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង

-បានអញ្ជើញចុះសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ និងជាដែនសមត្ថកិច្ចរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ដោយសហការជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីរៀបចំដំណើរការចុះបំពេញការងារនៅខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តពោធិ៍សាត់

-បានអញ្ជើញចុះសិក្សាឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈម នៃការអភិវឌ្ឍមូលដ្ឋាន ការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និង

វិសហាមជ្ឈការ និងការគ្រប់គ្រងច្រកទ្វារអន្តរជាតិ នៅខេត្តកណ្ដាល និងខេត្តស្វាយរៀង

-បានអញ្ជើញចុះសិក្សាឈ្វេងយល់អំពីការវិវត្តរីកចម្រើនថ្មី និងបញ្ហាប្រឈមរបស់ខេត្ត និងវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ចាម

-បានអញ្ជើញចុះសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ និងការផ្សព្វផ្សាយព័ត៌មាន នៅច្រកទ្វារព្រំដែនអន្តរជាតិជ្រៃធំ-ខ្នារតាំងយូរ ស្ថិតនៅស្រុកកោះធំ ខេត្តកណ្ដាល

-បានអញ្ជើញចុះជួបសំណេះសំណាលជាមួយអាជ្ញាធរ និងមន្ទីរពាក់ព័ន្ធជុំវិញខេត្តត្បូងឃ្មុំ ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តការងារនៅថ្នាក់ក្រោមជាតិ និងនាំយកមតិយោបល់ សំណូមពរ និងបញ្ហាប្រឈមទាំងពួងរបស់ក្រុមប្រឹក្សាឃុំក្នុងស្រុកតំបែរ ដើម្បីពិភាក្សា និងរកដំណោះស្រាយឲ្យឆ្លើយតបនឹងសំណូមពរ និងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ នៅខេត្តត្បូងឃ្មុំ។

## ២.២ មុខងារតំណាង

-បានទទួលពាក្យបណ្ដឹងចំនួន១០ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០៥ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន០៥ករណី និងកំពុងពិនិត្យសិក្សាចំនួន០៥ករណី រំលឹកជំរុញចំនួន០១ករណី ព្រមទាំងទទួលឯកសារ ពាក្យបណ្ដឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបចំនួន០៧ករណី

-បានអញ្ជើញចុះធ្វើវេទិកាថ្នាក់ស្រុកស្ដីពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន នៅស្រុកតំបែរ ខេត្តត្បូងឃ្មុំ

-បានអញ្ជើញជាអធិបតីក្នុងវេទិកាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ជាមួយនឹងក្រុមប្រឹក្សាសង្កាត់ក្រាំងធ្នង់ ក្រោមប្រធានបទស្ដីពី ការអភិវឌ្ឍមូលដ្ឋាន ធានាបាននូវការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ នៅសាលាសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំពិភាក្សាស្តីពី ការរៀបចំគម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២១ ជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **វង្សី វិស្សុត** រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានអញ្ជើញចូលរួមប្រជុំតាមរយៈ Video Conference ដើម្បីស្តាប់ការប្រកាសសេចក្តីសម្រេច និងផ្សព្វផ្សាយការត្រៀមរៀបចំចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤១ ដែលនឹងប្រព្រឹត្តទៅនាខែកញ្ញា ឆ្នាំ២០២០ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** ប្រធានគណៈកម្មការទី២ រដ្ឋសភា

-បានអញ្ជើញចូលរួមប្រជុំតាមរយៈ Video Conference ស្តីពីភាពជាដៃគូអន្តរសភាអាស៊ានលើកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំ និងវប្បធម៌ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមក្របខណ្ឌមហាសន្និបាតអន្តរសភាអាស៊ាន (AIPA)

-បានអញ្ជើញចូលរួមប្រជុំជាមួយឯកឧត្តមអគ្គនាយកលំនៅដ្ឋាន ដើម្បីពិភាក្សាលើការរៀបចំសៀវភៅណែនាំស្តីពី ការកែលម្អបច្ចេកទេសលំនៅដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់សហគមអ្នកក្រីក្រនៅកម្ពុជា ស្ថិតនៅទីស្តីការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់

-បានអញ្ជើញចូលរួមផ្តល់បទបង្ហាញអំពីតួនាទីស្ត្រី និងផែនការអភិវឌ្ឍ ក្នុងកិច្ចប្រជុំយុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ

-បានអញ្ជើញជួបពិភាក្សា និងស្តាប់បទបង្ហាញរបស់តំណាងអង្គការចលនាដើម្បីសុខភាពកម្ពុជា (CMH) ស្តីពីលទ្ធផល នៃការអង្កេតការអនុលោមតាមច្បាប់ ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់

-បានអញ្ជើញចូលរួមប្រជុំជាមួយមន្ត្រី ដើម្បីស្តាប់នូវសេចក្តីរាយការណ៍អំពីការងារដែលបានអនុវត្តរួច និងការងារដែលកំពុងអនុវត្ត ព្រមទាំងការងារដែលនៅសេសសល់ ព្រមទាំងកម្មវិធីប្រគល់ Computer ១០គ្រឿង និងម៉ាស៊ីនPrinter ចំនួន០៥គ្រឿងជូនវិទ្យាល័យសៀមប៉ាង ដែលជាអំណោយដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញចូលរួមសិក្ខាសាលាតាមប្រព័ន្ធវីដេអូ (Webinar) ជាមួយនឹងសមាជិក សមាជិការដ្ឋសភាក្នុងនាមសភាជាតិកម្ពុជាស្តីពី ផលប៉ះពាល់នៃជំងឺកូវីដ១៩ ចំពោះការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក សហការរៀបចំដោយសហភាពអន្តរសភា (IPU) និងគណៈកម្មការសេដ្ឋកិច្ច និងសង្គម របស់អង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិក (ESCAP)

-បានអញ្ជើញប្រជុំជាមួយក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់អំពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តត្បូងឃ្មុំ

-បានប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដើម្បីពិនិត្យសេចក្តីព្រាងរបាយការណ៍លទ្ធផលវេទិកាថ្នាក់ស្រុកស្តីពី ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន នៅស្រុកតំបែរ ខេត្តត្បូងឃ្មុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការសេដ្ឋកិច្ច (ក្រុមសភាជាតិកម្ពុជា) នៃមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤១ ដឹកនាំដោយ **ឯកឧត្តម សុខ សូកាន** ប្រធានគណៈកម្មាធិការសេដ្ឋកិច្ច ដើម្បីពិភាក្សាទៅលើសេចក្តីព្រាងសេចក្តីសម្រេចរួមស្តីពី តួនាទីសភាក្នុងការជំរុញភាពស្អិតរមួត និងការងើបឡើងវិញនៃសេដ្ឋកិច្ចអាស៊ាន នៅក្នុងដំណាក់កាលក្រោយជំងឺកូវីដ-១៩

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ (Covid-19) ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានាចំនួន ១៧៣លើក។

## ២.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** បានអញ្ជើញទទួលជួបពិភាក្សាការងាររវាងស្ថាបនិក

ទីលានបើកបរយានយន្តយ៉ាម៉ាម៉ូតូ និងអ្នកតំណាងសហព័ន្ធកីឡាយានយន្តកម្ពុជា និងលោក Yamamoto ស្តីពីការដាក់ឱ្យដំណើរការសាកល្បងប្រណាំងរថយន្តនៅតំបន់អភិវឌ្ឍន៍ម៉ុង ឫទ្ធី សែនជ័យ។

ថ្ងៃច័ន្ទ ៥រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

កិត្តិសង្គហបណ្ឌិត ទេព ងន

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ